# អារម្ភកថា លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី

យើងខ្ញុំសូមសំដែងនូវសេចក្តីកោតសរសើរ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការពលកម្មអន្តរជាតិ (ILO) ដែលបានខិតខំផលិតឯកសារបណ្តុះបណ្តាលដ៏មានសារៈប្រយោជន៍នេះឡើង។ នេះគឺជាការចាប់ផ្តើមបំពេញកង្វះខាតដ៏សំខាន់មួយ ផ្នែកធនធានឯកសារសំរាប់បណ្តុះបណ្តាលជាភាសាខ្មែរ ដើម្បីចូលរួមចំណែកលើកកំពស់ការអភិវឌ្ឍន៏សហគ្រាសខ្នាតមីក្រូ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។ មានស្ត្រីកម្ពុជាជាច្រើននាក់កំពុងមមាញឹកប្រកបអាជីវកម្មខ្នាតតូច តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅមិនទាន់បានទទួលការបណ្តុះបណ្តាល ឬការគាំទ្រដែលអាចជួយដល់ពួកគាត់អោយចេះចាប់ផ្តើម ឬធ្វើអោយអាជីវកម្មបានរីកចំរើននៅឡើយទេ។ ឯកសារបណ្តុះបណ្តាលអំពី ‘‘យេនឌ័រ និងភាពជាសហគ្រិនរួមគ្នាឆ្ពោះទៅមុខនេះ (GET Ahead)’’ មិនមែនគ្រាន់តែផ្តល់នូវសេចក្តីណែនាំអំពីជំនាញគ្រប់គ្រងអាជីវកម្មជាមូលដ្ឋានសំរាប់ស្ត្រី និងបុរសប៉ុណ្ណោះទេ ក៏ប៉ុន្តែបានកសាងនូវការយល់ដឹងយ៉ាងច្រើនអំពីបញ្ហាពាក់ព័ន្ធទៅនឹងយេនឌ័រ នៅក្នុងការអភិវឌ្ឍន៏សហគ្រាសខ្នាតតូច និងខ្នាតមីក្រូ និងទៅជាឧបករណ៏ដ៏មានប្រយោជន៏មួយសំរាប់ឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធទាំងនេះ។

ក្រសួងកិច្ចការនារីនឹងប្រើប្រាស់សំភារៈទាំងនេះ ដើម្បីកែប្រែមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៏អោយក្លាយទៅជាមជ្ឈមណ្ឌលពង្រឹងភាពអង់អាចរបស់ស្ត្រីបែបសមាហរ័ណកម្ម។ សិក្ខាសាលាបណ្តុះបណ្តាលអំពីយេនឌ័រ និងភាពជាសហគ្រិនរួមគ្នាឆ្ពោះទៅមុខនេះនឹងត្រូវយកទៅអនុវត្តនៅតាមមជ្ឈមណ្ឌលនានា ដើម្បីបំពេញតំរូវការបណ្តុះបណ្តាលជំនាញផ្សេងៗ ដែលមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៏កំពុងផ្តល់សព្វថ្ងៃនេះ។ យើងខ្ញុំសូមកោតសរសើរយ៉ាងខ្លាំងចំពោះប្រភេទសំភារៈបណ្តុះបណ្តាលដែលមានលក្ខណៈបែបចូលរួម និងបែបតំរង់ទិសសកម្មភាពដូចបានរៀបរាប់ខាងលើនេះ ហើយជាក់ស្តែងទៅទៀតនោះគឺថា សំភារៈទាំងនេះអាចកែច្នៃតំរូវទៅតាមករិតវប្បធមិរបស់អ្នកចូលរួម ឬសិក្ខាកាមទោះបីជាពួកគេចេះអាន និងចេះសរសេរអក្សរតិចតួចក៏ដោយ។ ម៉្យាងទៀត ចំពោះការណែនាំយ៉ាងល្អិតល្អន់សំរាប់វគ្គសិក្សានីមួយៗ ដែលសំភារៈបណ្តុះបណ្តាលនេះ ហាក់ដូចជាថ្មីស្រឡាងចំពោះអ្នក

# អារម្ភកថា

បណ្តុះបណ្តាលមែនតែតាមរយៈការពន្យល់ និងការលើកយកឧទាហរណ៏ជាក់ស្តែងមួយចំនួនមកឆ្លុះបញ្ចាំង វាបានធ្វើអោយអ្នកបណ្តុះបណ្តាលកាន់តែមាន ការអភិវឌ្ឍន៏ជំនាញ និងភាពជឿជាក់របស់ខ្លួនដើម្បីយកទៅបើកវគ្គសិក្ខាសាលាបណ្តុះបណ្តាលស្តីពី GET Ahead អោយកាន់មានប្រសិទ្ធិភាពឡើង។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Gerry Finnegan ដែលបានខិតខំប្រឹងប្រែងចូលរួមវិភាគទាន ក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរបស់ក្រសួង ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ រួមទាំងការចូលរួមរៀបចំឯកសារបណ្តុះបណ្តាលដ៏មានតំលៃនេះផងដែរ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះការចូលរួមរបស់លោក លោកស្រី ដែលមកពីគំរោងអង្គការពលកម្មអន្តរជាតិ (ILO) គំរោងធនាគារអភិវឌ្ឍន៏អាស៊ី (ADB) រួមជាមួយនឹងក្រសួងដែលបានខិតខំរៀបចំធនធានទាំងនេះរួមគ្នា ដើម្បីបកប្រែ និងសាកល្បងបណ្តុះបណ្តាលសំភារៈទាំងនេះ និងធ្វើអោយមានលក្ខណៈកាន់តែងាយស្រួលសំរាប់ក្រសួង ក៏ដូចជាសំរាប់ការអភិវឌ្ឍន៏សហគមន៏អោយកាន់តែរីកចំរើនឡើង នៅក្នុងប្រទេសកម្ពុជា ជាពិសេស លោកស្រី Nelien Haspels នៃអង្គការពលកម្មអន្តរជាតិ ការិយាល័យអនុតំបន់សំរាប់អាស៊ីអាគ្នេយ៏ លោកស្រី យង់ វីន មន្ត្រីសំរបសំរួលថ្នាក់ជាតិរបស់គំរោង ILO/Japan's EEOW ប្រចាំប្រទេសកម្ពុជា លោកស្រី Maria Jose Barney អ្នកជំនាញការ ILO សំរាប់គំរោងសាកល្បងជាមួយមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៏ ខេត្តកំពង់ឆ្នាំង (NEEEW) ឧបត្ថម្ភថវិកាដោយ ILO/Ireland និង លោកស្រី Cheryl Urashima និងលោកស្រី អ៊ុច សារុម ជាទីប្រឹក្សាប្រចាំក្រសួង ក្រោមជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៏អាស៊ីសំរាប់គំរោងលើកស្ទួយមុខរបរស្ត្រីក្រីក្រអោយមាននិរន្តរភាព ដែលឧបត្ថម្ភថវិកាដោយនាយកដ្ឋានសំរាប់ការអភិវឌ្ឍន៏អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID)។ យើងខ្ញុំសូមថ្លែងអំណរគុណវិទ្យាស្ថាន VBNK ចំពោះកិច្ចសហការជាមួយអង្គការ ILO និង ADB ក្នុងការសាកល្បងបណ្តុះបណ្តាល GET Ahead ជាអត្ថបទភាសាខ្មែរ ហើយបានយល់ព្រមធ្វើការជាមួយ យើងខ្ញុំនៅក្នុងការរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) អោយដល់មជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៏ គ្រូបង្គោលនៅក្នុងក្រសួង និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។

## អារម្ភកថា

យើងខ្ញុំសង្ឃឹមថា អង្គការ ILO និង ADB TA នឹងខិតខំធ្វើអោយសំភារៈទាំងនេះមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណ និងសូមជូនពរដល់អ្នកបណ្តុះបណ្តាលនៃនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ក្រសួង បុគ្គលិកមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលជាដៃគូ នៅក្នុងកម្មវិធី EEOW ទាំងអស់ សូមទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ហើយយើងខ្ញុំសង្ឃឹមថា អ្នកបណ្តុះបណ្តាលមកពីអង្គការដទៃទៀតនឹងប្រើឯកសារនេះ ដើម្បីជួយស្ត្រី និងបុរសក្រីក្រនៅទូទាំងប្រទេស អោយរួចចាកផុតពី ភាពក្រីក្រ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យជូនដល់លោកស្រី អស់លោក អ្នកនាង ដែលនឹងចូលរួមនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាល GET Ahead នេះទាំងអស់ សូមបានទទួលជោគជ័យនៅក្នុងការធ្វើអោយអាជីវកម្ម ក៏ដូចជា មានជីវភាពធូរធារ ចំរើនរុងរឿងក្នុងជីវិត និងជួបប្រទះនូវពុទ្ធពរទាំង៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខែ វិច្ឆិកា ឆ្នាំ ២០០៤

លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី

រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី

នៃរាជរដ្ឋាភិបាលកម្ពុជា

## បុព្វកថា អង្គការពលកម្មអន្តរជាតិ (ILO)

ឯកសារបណ្តុះបណ្តាលស្តីពី **យេនឌ័រ និងភាពជាសហគ្រិនរួមគ្នាឆ្ពោះទៅមុខសំរាប់ស្ត្រីនៅក្នុងសហគ្រាស (GET Ahead for Women in Enterprise)** មានគោលបំណងជួយដល់អង្គការនានាដែលជាដៃគូរបស់អង្គការពលកម្មអន្តរជាតិ (ILO) ក្នុងការលើកកំពស់កិច្ចអភិវឌ្ឍន៏សហគ្រាស ក្នុងចំណោមស្ត្រីដែលស្ថិតនៅក្នុងស្ថានភាពក្រីក្រ ដែលចង់ចាប់ផ្តើម ឬបានធ្វើអាជីវកម្មខ្នាតតូចរួចហើយ។ ឯកសារបណ្តុះបណ្តាលអំពីយេនឌ័រ និងភាពជាសហគ្រិន (GET Ahead) មានលក្ខណៈខុសពីឯកសារបណ្តុះបណ្តាលអាជីវកម្មធម្មតា ដោយបង្ហាញពីជំនាញនៃភាពជាសហគ្រិនសំខាន់ៗចេញពីទស្សនៈយេនឌ័រ ថាតើវាឆ្លើយតបទៅនិងការចាប់ផ្តើម ឬការធ្វើអោយរីកចំរើននូវអាជីវកម្មជាលក្ខណៈបុគ្គលជាគ្រួសារ ឬជាក្រុម ដែរឬទេ។ វាដោះស្រាយតំរូវការចំពោះមុខ និងតំរូវការជាយុទ្ធសាស្ត្ររបស់ស្ត្រីដែលរកបានប្រាក់ចំណូលតិចតួចតាមរយៈការពង្រឹងជំនាញគ្រប់គ្រងអាជីវកម្មជាមូលដ្ឋាន និងជំនាញគ្រប់គ្រងមនុស្ស។ វាបង្ហាញស្ត្រីអំពីរបៀបអភិវឌ្ឍ លក្ខណៈពិសេសនៃភាពជាសហគ្រិនផ្ទាល់ខ្លួនរបស់គេម្នាក់ៗ និងការទទួលបាននូវការគាំទ្រតាមរយៈក្រុម បណ្តាញការងារ និង ស្ថាប័ននានាដែលទាក់ទងជាមួយនិងការអភិវឌ្ឍន៏សហគ្រាស។

ឯកសារនេះឆ្លុះបញ្ចាំង និងបំពេញនូវភាពសំបូរបែបខាងបទពិសោធន៏ដែលមាននៅក្នុងអង្គការ ILO អង្គការ UNIFEM និងអង្គការ GTZ និងអង្គការផ្សេងៗទៀត។ វាប្រើប្រាស់ឯកសារទូទៅមួយចំនួន ដូចជា ឧបករណ៏ទាំងឡាយដែលបានបង្កើតឡើងដោយគំរោង ‘ចាប់ផ្តើម និងធ្វើអោយអាជីវកម្មរបស់អ្នករីកចំរើន’ របស់អង្គការ ILO (SIYB) និងកម្មវិធីហិរញ្ញវត្ថុសង្គម និងផ្តល់នូវការទំនាក់ទំនងទៅនិងធនធានសំខាន់ៗដទៃទៀតរបស់អង្គការ ILO ដូចជា ការកសាងសមាគម និងលក្ខខ័ណ្ឌការងារប្រកបដោយសុវត្ថិភាព ដែលជាក្តីព្រួយបារម្ភយ៉ាងខ្លាំងសំរាប់ស្ត្រីជាសហគ្រិន ជាពិសេស នៅក្នុងសហគ្រាសខ្នាតតូច និងខ្នាតមីក្រូនៅ ក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ។

ការបណ្តុះបណ្តាលអំពី **យេនឌ័រ និងភាពជាសហគ្រិន (GET Ahead)** ជំរុញអោយមានភាពអង់អាចផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រីអោយស្មើគ្នានិងបុរស នៅក្នុងសហគ្រាស :

- **ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច** ពីព្រោះ ស្ត្រីក្រីក្រជាប់រវល់តែនៅក្នុងការងាររកប្រាក់ចំណូល ហេតុនេះ ជាធម្មតា គាត់មានឱកាសតិចតួចសំរាប់ការអប់រំ និងការបណ្តុះបណ្តាលនានា។ ពួកគាត់ច្រើនតែទទួលបន្ទុកការងារទ្វេមួយជាពីរ ឬជាបី ដោយត្រូវទទួលខុសត្រូវទាំងលើសកម្មភាពសេដ្ឋកិច្ច និងការថែទាំគ្រួសារ។ ពួកគាត់ត្រូវការជំនាញគ្រប់គ្រង និងជំនាញក្នុងការចរចារ ដើម្បីកែប្រែសកម្មភាពរស់នៅប្រចាំថ្ងៃ អោយទៅជាអាជីវកម្មផលិតកម្ម និងអាចរកប្រាក់ចំណេញបានច្រើនសំរាប់ដំណើរការអាជីវកម្មរយៈពេលយូរ។
- **ការពង្រឹងភាពអង់អាចផ្នែកសង្គម** ពីព្រោះស្ត្រីនៅក្នុងប្រទេសជាច្រើនមានឋានៈតូចតាច បើប្រៀបធៀបទៅនឹងបុរស។ ស្ត្រីភាគច្រើននៅតែផ្ទះ ខ្វះការទំនាក់ទំនងជាមួយនិងពិភពខាងក្រៅ និងប្រឈមមុខនឹងភាពចល័ត និងឧបសគ្គក្នុងការបង្កើតបណ្តាញ។ ស្ត្រីត្រូវការជំនាញកសាងភាពជឿជាក់ និងជំនាញក្នុងការបង្កើតបណ្តាញការងារ ដើម្បីអោយពួកគេមានការទុកចិត្តទៅលើការវិនិច្ឆ័យ និងជឿជាក់ទៅលើភាពខ្លាំងរបស់ពួកគេផ្ទាល់។

ការបណ្តុះបណ្តាលអំពី **យេនឌ័រ និងភាពជាសហគ្រិន** ផ្តោតជាចំបងទៅលើស្ត្រីជាសហគ្រិន ក៏ប៉ុន្តែ គេក៏មិនភ្លេចបុរស ដែរ។ សុភាសិតទូទៅដែលគេប្រើទូទាំងពិភពលោក និយាយថា *‘នៅខាងក្រោយបុរសដែលប្រកបដោយភាពជោគជ័យ តែងតែមានស្ត្រីខ្លាំងម្នាក់ជានិច្ច’*។ សុភាសិតនេះ នៅតែមានតំលៃជានិច្ច។ ទោះជាស្ត្រីជាផ្នែកមួយនៃអាជីវកម្មគ្រួសារ ឬគេរកស៊ីដោយខ្លួនឯង ឬជាមួយក្រុមស្ត្រីផ្សេងទៀតក៏ដោយ ក៏ភាពជោគជ័យរបស់ពួកគេតែងតែពឹងផ្អែកទៅលើការទទួលបានការគាំទ្រ និងការលើកទឹកចិត្តពីសំណាក់គ្រួសាររបស់គេ ផងដែរ។ ហេតុដូចនេះហើយ ឯកសារនេះមិនមែនផ្តោតទៅលើតែស្ត្រីនោះទេ ប៉ុន្តែវាផ្តោតទៅលើយេនឌ័រជាក់លាក់មួយ (Gender-specific)។

វិធីសាស្ត្របណ្តុះបណ្តាល គឺជាវិធីសាស្ត្រដែលមានលក្ខណៈបែបចូលរួម និងបែបតំរង់ទិសសកម្មភាព ដោយប្រើប្រាស់បទពិសោធន៏ក្នុងឆាកជីវិតជាក់ស្តែងរបស់សិក្ខាកាម ហើយកសាងវិធីសាស្ត្រទាំងនេះសំរាប់ជាមេរៀនស្តីពីការគ្រប់គ្រងអាជីវកម្មអោយកាន់តែប្រសើរឡើង។ ស្ត្រី និងបុរសជាអាជីវករ ក៏ដូចជាសមាគមអាជីវកម្មរបស់គេបានផ្តល់ការចូលរួមវិភាគទានយ៉ាងសំខាន់ចំពោះការបណ្តុះបណ្តាលនេះ។ ឯកសារបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងជារចនាសម្ព័ន្ធដែលមានជាសំណុំមេរៀនជាមួយនិងការរៀនសូត្រអនុវត្តន៏ និងការធ្វើលំហាត់ ដែលបង្ហាញពីការអភិវឌ្ឍន៏អាជីវកម្ម និងការទំនាក់ទំនងយេនឌ័រ។ លំហាត់នេះ ប្រើប្រាស់ទាំងធនធាន និងគំនិតរួមគ្នាដែលបង្ហាញពីប្រសិទ្ធិ

## មុខកថា

ភាព និងភាពសមស្រប សំរាប់ស្ត្រីដែលមានប្រាក់ចំណូលទាប និងមានការអប់រំក្នុងប្រព័ន្ធបានតិចតួច ក៏ដូចជាសំរាប់អ្នកគ្រប់គ្រងជាន់ខ្ពស់នៅក្នុងស្ថាប័នរដ្ឋ និងផ្នែកឯកជនផងដែរ។ ក្រុមទាំងនេះ ប្រឈមមុខនឹងឧបសគ្គប្រហាក់ប្រហែលគ្នា នៅពេលពួកគេចូលមកធ្វើការងារគ្រប់គ្រង ដូចជា ការមានពេលវេលាតិចតួច និងការថ្លឹងថ្លែងតំរូវការចាំបាច់ កំលាំងថាមពល និងការយកចិត្តទុកដាក់ ជាដើម។

ការបណ្តុះបណ្តាលអំពីយេនឌ័រ និងភាពជាសហគ្រិនរួមគ្នាឆ្ពោះទៅមុខ សំរាប់ស្ត្រីនៅក្នុងសហគ្រាស បានចាប់ផ្តើមធ្វើសាកល្បងលើកដំបូងនៅប្រទេសថៃ ក្នុងឆ្នាំ២០០១។ ការបណ្តុះបណ្តាលនេះ បានពង្រីក និងបានសាកល្បងនៅតាមមូលដ្ឋាននៅប្រទេសកម្ពុជា និងប្រទេសឡាវ ក្នុងឆ្នាំ២០០៣។ គំនិតផ្តួចផ្តើមនេះ ត្រូវបានអនុវត្តដោយក្រុមការងារនៃគំរោងយេនឌ័រ និងបញ្ហារបស់កម្មការិនីរបស់អង្គការ ILO ការិយាល័យអនុតំបន់អាស៊ីខាងកើត (SRO-Bangkok) និងក្រុមការងារនៃគំរោងការអភិវឌ្ឍន៏ភាពជាសហគ្រិនរបស់ស្ត្រី និងសមភាពយេនឌ័រ (WEDGE) នៃកម្មវិធី InFocus ស្តីពីការបង្កើនការងារតាមរយៈកម្មវិធីអភិវឌ្ឍន៏សហគ្រាសខ្នាតតូច (IFP/SEED)។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ Nelien Haspels, Gerry Finnegan និង Susanne Bauer សំរាប់ការប្តេជ្ញាចិត្ត និងភាពជាអ្នកដឹកនាំរបស់ពួកគេក្នុងការផលិតឯកសារបណ្តុះបណ្តាលនេះឡើង។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះជំនួយហិរញ្ញវត្ថុ ដែលបានផ្តល់ដោយរដ្ឋាភិបាលនៃប្រទេសអៀរឡង់ ជប៉ុន និងចក្រភពអង់គ្លេស ដែលបានជួយបំពេញបន្ថែមនូវបច្ចេកទេស និងបដិភាគហិរញ្ញវត្ថុ ដល់អង្គការពលកម្មអន្តរជាតិ (ILO)។

យើងខ្ញុំសង្ឃឹមថា អង្គការដៃគូជាច្រើនទៀតរបស់អង្គការពលកម្មអន្តរជាតិ (ILO) នឹងគិតគូរពីអត្ថប្រយោជន៏របស់ GET Ahead ដើម្បីផ្តល់នូវការឧបត្ថម្ភដ៏មានប្រសិទ្ធិភាពដល់ក្រុមដែលបាត់បង់ផលប្រយោជន៏ និងធ្វើការកែលំអគុណភាពការងារ និងជីវិតរបស់គេ។

ខែមិនា ឆ្នាំ២០០៤ ទីក្រុងបាងកក និង ទីក្រុងហ្សឺណែវ
March 2004, Bangkok and Geneva

Christine Evans-Klock
Director
Subregional Office for East Asia
ILO, Bangkok

Michael Henriquer
Director
Department of Job Creation &
Enterprise Development
ILO, Geneva

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណ ចំពោះសិក្ខាកាមទាំងអស់ ដែលបានចូលរួមនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលស្តីពីយេនឌ័រ និងភាពជាសហគ្រិន (GET Ahead) សំរាប់ស្ត្រីនៅក្នុងសហគ្រាស នៅប្រទេសកម្ពុជា និងប្រទេសឡាវ ក្នុងឆ្នាំ២០០៣ និងប្រទេសថៃ ក្នុងឆ្នាំ ២០០១ និងសូមថ្លែងអំណរគុណចំពោះសហការី និងគ្រូបណ្តុះបណ្តាល ដែលមកពីអង្គការពលកម្មអន្តរជាតិបាងកក និងគំរោងនានារបស់អង្គការពលកម្មអន្តរជាតិថ្នាក់តំបន់ ក៏ដូចជាថ្នាក់ជាតិ និងស្ត្រីជាអាជីវករទាំងឡាយ។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ដែលជាអ្នកទទួលបន្ទុកការងារកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រពង្រឹងភាពអង់អាចដល់ស្ត្រី ក៏ដូចជាទីប្រឹក្សាផ្នែកអាជីវកម្ម អ្នកឯកទេសខាងយេនឌ័រនិងមនុស្ស និងអង្គការជាច្រើនទៀត ដែលបានចែករំលែកបទពិសោធន៍ និងសំភារៈរបស់ខ្លួនជាមួយនឹងពួកយើង។

គំរោងបានទទួលវិភាគទានពីថ្នាក់តំបន់នៅអាស៊ី រួមមាន ILO-Development Cooperation Ireland (DCI) Partnership Programme; the ILO/Japan Programme : Expansion of Employment Opportunities for Women (EEOW) ក្នុងប្រទេសកម្ពុជា និងប្រទេសថៃ និង the Mekong Sub-regional Project to Combat Trafficking in Children and Women (TICW) of the International Programme on the Elimination of Child Labor (IPEC) នៅប្រទេសឡាវ និងប្រទេសថៃ។

សូមថ្លែងអំណរគុណដល់មនុស្សជាច្រើនទៀត ដែលបានផ្តល់ពេលវេលា និងការព្យាយាមយ៉ាងខ្លាំងក្លា ដើម្បីអភិវឌ្ឍឯកសារបណ្តុះបណ្តាលនេះឡើង ទោះបីជាគេមានភារកិច្ចមមាញឹកក៏ដោយ។ ជាពិសេសសូម ថ្លែងអំណរគុណដល់ Sugunya Voradilokkul, Busakorn Suriyasarn, Aya Matsuura, Linda Deelen, Piyamal Pichaiwongse, Soe Le Aung, Max Iacono, Arita Charoensuk, Supinda Mongkhonsuksawat and Louis Boosinsukh in Thailand; Tim Dyce, Maria-Jose Barney and Akemi Serizawa in Geneva; Young Vin, Chi Sovanna, Nivana Cheng, Lim Phai and Bunchhit Veasna in Cambodia; Manisoth Bouddakham, Sengmany Viyaket, Phimphone Singsouliya, Inthasone Phetsiriseng and Phetphim Champasith in Lao PDR, Jens Christensen in Hanoi, as well as Maria Jose Barney; and our partners Sabine Becker, Gerry's wife name and Hanz Matla.

# សេចក្តីថ្លែងអំណរគុណ

ផលិតកម្មមេរៀនបណ្តុះបណ្តាលជាភាសាខ្មែរនេះ បានការគាំទ្ររួមគ្នាដោយអង្គការ ILO/EEOW នៅប្រទេសកម្ពុជា ជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ី ចំពោះក្រសួងកិច្ចការនារីរបស់គំរោងលើកស្ទួយមុខរបរស្ត្រីក្រីក្រអោយមាននិរន្តរភាព (ADB TA No. 3947-CAM) និងអង្គការ ILO/Ireland ជំនួយចំពោះមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចការអភិវឌ្ឍន៍ ខេត្តកំពង់ឆ្នាំង ដើម្បីធ្វើសមាហរ័ណកម្ម ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច ភាពជាសហគ្រិន និងការងារសំរាប់ស្ត្រីនៅក្នុងប្រទេសកម្ពុជា (NEEEW) ។

ឯកសារបណ្តុះបណ្តាល និងការបកប្រែជាភាសាខ្មែរនេះ ត្រូវបានពិនិត្យឡើងវិញ និងកែសំរួលដោយក្រុមអ្នកត្រួតពិនិត្យ រួមមាន លោកស្រី យង់ វីន មន្ត្រីសំរបសំរួលគំរោងថ្នាក់ជាតិរបស់អង្គការ ILO/EEOW លោកស្រី អ៊ុច សារុម អ្នកឯកទេសបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិកក្រុមជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ី (ADB TA) លោកស្រី Cheng Nivana អ្នកគ្រប់គ្រងអង្គការ Lotus Pond និងលោក លឹម ផៃ នាយកប្រតិបត្តិអង្គការ Urban Sector Group (USG) ដែលធ្លាប់ធ្វើជាអ្នកសំរបសំរួលនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលកាលពីខែមិនា ឆ្នាំ២០០៣ នៅប្រទេសកម្ពុជា។ ឯកសារបណ្តុះបណ្តាលនេះ បានបកប្រែជាភាសាខ្មែរដោយ **លោក មៀម សុតន្ទ** សមាជិកក្រុមជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ី (ADB TA) និង **កញ្ញា ប៉ែង ដាវុធកល្យាណ** ក្រោមការណែនាំ និងការគាំទ្ររបស់លោកស្រី **Cheryl Urashima** ប្រធានក្រុម ការងារជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ី (ADB TA) ។

អត្ថបទជាភាសាខ្មែរនេះ បានយកទៅធ្វើសិក្ខាសាលាបណ្តុះបណ្តាលសាកល្បងបន្ថែមទៀតនៅនឹងមូលដ្ឋានផ្ទាល់តែម្តង នៅក្នុងខែកញ្ញា ឆ្នាំ២០០៤ ដែលបានសំរបសំរួលដោយវិទ្យាស្ថានបណ្តុះបណ្តាលសំរាប់អ្នកគ្រប់គ្រងការអភិវឌ្ឍន៍នៅកម្ពុជា (VBNK) ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើន ចំពោះគ្រូបណ្តុះបណ្តាលរបស់ VBNK និងសិក្ខាកាមទាំងឡាយដែលបានបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ ខេត្តកំពង់ឆ្នាំង ដែលបានចូលរួមនៅក្នុងសិក្ខាសាលានេះ ក៏ដូចជាលោកស្រី ម៉ែន អេន នាយកមជ្ឈមណ្ឌល ដែលបានរៀបចំអោយមានសិក្ខាសាលានៅក្នុងមជ្ឈមណ្ឌលរបស់គាត់ ។

# សេចក្តីថ្លែង អំណរគុណ

សូមថ្លែងអំណរគុណជាពិសេសផងដែរ ចំពោះលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងលោកជំទាវ កេត សំអាត អគ្គនាយក ក្រសួងកិច្ចការនារី ដែលបានជួយលើកទឹកចិត្តអោយមានកិច្ចសហការគ្នារវាងអង្គការ ILO និង ADB នៅក្នុងកិច្ចប្រឹងប្រែងធ្វើកិច្ចការទាំងនេះ។

Susanne Bauer, Gerry Finnegan and Nelien Haspels
ខែ វិច្ឆិកា 2004, Berlin, Geneva and Bangkok